00221246

A190/I/4

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
# នៅចំពោះមុខអង្គបុរេជំនុំជម្រះ

| | | |
|---|---|---|
| សំណុំរឿងលេខ | ៖ | ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ-១១) |
| កាលបរិច្ឆេទនៃឯកសារ | ៖ | ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨ |
| ភាគីបញ្ជូន | ៖ | ការិយាល័យសហព្រះរាជអាជ្ញា |
| ភាសាដើម | ៖ | អង់គ្លេស |
| ប្រភេទឯកសារ | ៖ | សាធារណៈ |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 28 / Aug / 2008
ម៉ោង (Time/Heure): 09 : 40
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

## ចម្លើយតបរបស់ សហព្រះរាជអាជ្ញា
## ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ស្តីពី
## សិទ្ធិ និង ភាតព្វកិច្ចរបស់ភាគី ទាក់ទងនឹងការបកប្រែ

---

<u>**បញ្ជូនដោយ៖**</u>

**ការិយាល័យហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Robert PETIT

លោក យ៉េត ចរិយា

លោក William SMITH

លោក ពេជ្រ សម្បត្តិ

លោក Alex Bates

លោក Anees AHMED

<u>**ចែកចាយជូន៖**</u>

**អង្គបុរេជំនុំជម្រះ៖**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម Rowan DOWNING

ចៅក្រម ន័យ ថុល

ចៅក្រម Katinka LAHUIS

ចៅក្រម ហួត វុទ្ធី

**មេធាវីការពារក្តីរបស់ភាគីប្តឹងឧទ្ធរណ៍ ខៀវ សំផន៖**

លោក ស សូវាន

លោក Jacques VERGES

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ ធ្វើការបញ្ជាក់ (Certified Date/Date de certification): 28 / 08 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fry

## ១. សេចក្ដីផ្ដើម

១. នៅក្នុងសេចក្ដីសម្រេចមួយ ដែលពណ៌នាអំពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែក្នុងអំឡុងពេលនៃការស៊ើបសួរ ("សេចក្ដីសម្រេចទាក់ទងនឹងការបកប្រែ") សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចថា គេត្រូវផ្ដល់ជូនដល់ជនត្រូវចោទជាភាសាដែលជនត្រូវចោទយល់បាន៖ ទី១) ដីកាបញ្ជូនរឿងទៅជំនុំជម្រះដោយមានធាតុផ្សំជាភស្ដុតាង ដែលជាមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ និងទី២) ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានស្ថាពរ ដោយមានលិបិក្រមនៃធាតុផ្សំអង្គហេតុ ដែលជាមូលដ្ឋាននៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានស្ថាពរ[1] ។ ដោយកត់សម្គាល់ឃើញថាសមត្ថភាពក្នុងការបកប្រែរបស់ផ្នែកគ្រប់គ្រងតុលាការមានកំណត់ សហចៅក្រមស៊ើបអង្កេតបានតម្រូវផងដែរថា ក្រុមមេធាវីការពារក្ដីត្រូវកាត់បន្ថយតម្រូវការនៃការបកប្រែរបស់ខ្លួន ដោយប្រើប្រាស់នូវសមត្ថភាពផ្នែកភាសាវិទ្យានៅក្នុងក្រុមរបស់ខ្លួន និងនៅក្នុងផ្នែកគាំទ្រការការពារមេធាវី[2] ។ សហចៅក្រមស៊ើបអង្កេត ក៏បានបង្គាប់ផងដែរថាគេត្រូវផ្ដល់អ្នកបកប្រែណាម្នាក់ដោយមិនគិតកម្រៃ ឲ្យផ្ដល់សេវាដល់ក្រុមការពារក្ដីនីមួយៗ[3] ។

២. ជនត្រូវចោទឈ្មោះ ខៀវ សំផន ស្វែងរកការបដិសេធសេចក្ដីសម្រេចទាក់ទងនឹងការបកប្រែ ដោយលើកជាសំអាងថា៖ ទី១) វាបំពានលើសិទ្ធិរបស់គាត់ ដោយមិនបានផ្ដល់ឯកសារទាំងនោះជាភាសាបារាំង ដែលជាភាសារបស់មេធាវីការពារក្ដីអន្តរជាតិរបស់គាត់, និងទី២) ការប្ដូរបញ្ច្រាសដោយភ័ន្តច្រឡំនូវបន្ទុកក្នុងការបកប្រែឯកសារ ពីខាងតុលាការទៅឲ្យខាង

[1] *ករណីរបស់ ខៀវ សំផន,* ដីកាសម្រេចរបស់ ក.ស.ច.ស ស្ដីពី សិទ្ធិ និងកាតព្វកិច្ចរបស់ភាគី ទាក់ទងនឹងការបកប្រែ, សំណុំរឿងព្រហ្មទណ្ឌលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ចុះថ្ងៃទី២៣ មិថុនា ២០០៨, លេខERN 00196923-00196930, A/90 កថាខណ្ឌ B4 [*បន្ទាប់ពីនេះទៅហៅថា៖* សេចក្ដីសម្រេចទាក់ទងនឹងការបកប្រែ] ។

[2] សេចក្ដីសម្រេចទាក់ទងនឹងការបកប្រែ, កថាខណ្ឌ A4 ។

[3] សេចក្ដីសម្រេចទាក់ទងនឹងការបកប្រែ, កថាខណ្ឌ B2-B3 ។

មេធាវីការពារក្តី ។ ដោយបានអះអាងអំពីការបំពានលើនីតិវិធី ខៀវ សំផន ស្វែងរកនូវការដោះលែងមួយពីការឃុំខ្លួនដោយគ្មានលក្ខខណ្ឌ[4] ។

៣. សហព្រះរាជអាជ្ញា ស្នើឱ្យ អង្គបុរេជំនុំជម្រះ បដិសេធបណ្តឹងឧទ្ធរណ៍នេះចោល ។ បណ្តឹងឧទ្ធរណ៍នេះមិនអាចទទួលយកបានទេ ព្រោះថា សេចក្តីសម្រេចទាក់ទងនឹងការបកប្រែនេះ មិនមែនជាសេចក្តីសម្រេចមួយដែលស្ថិតនៅក្នុងប្រភេទទាំងឡាយ ដែលបានកំរិតឱ្យជនត្រូវចោទអាចប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះបាននោះទេ[5] ។ បើមិនដូច្នោះទេ បណ្តឹងឧទ្ធរណ៍នេះក៏មិនគួរនឹងទទួលយកដែរ ព្រោះថា៖ ទី១) ច្បាប់កំពុងអនុវត្ត និងបទដ្ឋានអន្តរជាតិ ដែលពាក់ព័ន្ធនឹងសិទ្ធិទទួលបាននូវការកាត់ក្តីដ៏ត្រឹមត្រូវ តម្រូវឱ្យមានការបកប្រែឯកសារជាក់លាក់តែមួយចំនួនប៉ុណ្ណោះ (មិនមែនទាំងអស់នោះទេ) ឱ្យទៅជាភាសាមួយដែលចុងចោទយល់បាន, ទី២) ចុងចោទមិនមានសិទ្ធិឱ្យគេបកប្រែគ្រប់ឯកសារទាំងអស់ ឱ្យទៅជាភាសារបស់ក្រុមមេធាវីអន្តរជាតិរបស់ខ្លួននោះទេ ជាពិសេស នៅពេលដែលក្រុមមេធាវីការពារក្តី និងផ្នែកគាំពារការពារក្តីមានសមត្ថភាពផ្នែកភាសាវិទ្យាគ្រប់គ្រាន់រួចទៅហើយនោះ, ទី៣) បញ្ញត្តិស្តីពីអ្នកបកប្រែដោយមិនគិតកម្រៃ បន្ថែមឱ្យទៅខាងក្រុមមេធាវីការពារក្តីនោះ មិនបានបដិសេធសមភាពនៃអំណាច [រវាងការដាក់ និងដោះបន្ទុក]នោះទេ ក៏ប៉ុន្តែបានបន្ថែមទៅលើសមត្ថភាពផ្នែកភាសាវិទ្យារបស់ខ្លួនទៅវិញទេ, និងទី៤) ដោយហេតុថា សេចក្តីសម្រេចទាក់ទងនឹងការបកប្រែ មិនបំពានលើសិទ្ធិណាមួយរបស់ភាគីប្តឹងឧទ្ធរណ៍ក្នុងការទទួលបាននូវការកាត់ក្តីដោយយុត្តិធម៌ ហើយក៏មិនមានការបំពានលើនីតិវិធីដែលតម្រូវឱ្យមានជាដំណោះស្រាយណាមួយទេ នោះគឺមិនអាចមានការដោះលែងដោយគ្មានលក្ខខណ្ឌទាល់តែសោះ ។

---

[4] *ករណីរបស់ ខៀវ សំផន,* សារណាបណ្តឹងឧទ្ធរណ៍របស់ក្រុមការពារក្តី ចំពោះការបដិសេធសំណើសុំបកប្រែសំណុំរឿងព្រហ្មទណ្ឌរបស់លោក ខៀវ សំផន, សំណុំរឿងព្រហ្មទណ្ឌលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ-១១) ចុះថ្ងៃទី២២ កក្កដា ២០០៨, កថាខណ្ឌទី ៧ [*បន្ទាប់ពីនេះទៅហៅថា៖* បណ្តឹងឧទ្ធរណ៍] ។

[5] វិធាន ៧៤.៣ នៃវិធានផ្ទៃក្នុង [*បន្ទាប់ពីនេះទៅហៅថា៖* វិធាន] ។

## ២. សំណើពីដំបូងៗ

*មិនតម្រូវឱ្យមានសវនាការផ្ទាល់មាត់ទេ*

៤. សហព្រះរាជអាជ្ញា ស្នើថា ពុំចាំបាច់មានសវនាការផ្ទាល់មាត់ទេ ព្រោះថា ភាគីនានាធ្លាប់បានដាក់សារណាស្តីពីអង្គហេតុ និងអង្គច្បាប់ពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍នេះយ៉ាងគ្រប់គ្រាន់ជូនទៅអង្គបុរេជំនុំជម្រះរួចហើយ ។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញា ស្នើឱ្យ អង្គបុរេជំនុំជម្រះ សម្រេចកំណត់បណ្តឹងឧទ្ធរណ៍នេះ ត្រឹមតែជាសេចក្តីសំអាងជាលាយលក្សអក្សរប៉ុណ្ណោះបានហើយ ។ សេចក្តីណែនាំអនុវត្តសម្រាប់ការដាក់ឯកសារ ("សេចក្តីណែនាំអនុវត្ត") និងការអនុវត្តន៍របស់អង្គបុរេជំនុំជម្រះលើករណីស្រដៀងគ្នានេះបានអនុញ្ញាតឱ្យប្រើអំណាចបែបនេះ[6] ។

៥. ដើម្បីជាផលប្រយោជន៍សេដ្ឋកិច្ចរបស់អង្គជំនុំជម្រះនេះ សហព្រះរាជអាជ្ញា ស្នើឱ្យធ្វើការសម្រេចលើបណ្តឹងឧទ្ធរណ៍នេះ រួមគ្នាជាមួយនឹងបណ្តឹងឧទ្ធរណ៍ដែល អៀង សារី បានដាក់ជូនស្តីពីសេចក្តីសម្រេចទាក់ទងនឹងការបកប្រែនេះដែរ[7] ។ បណ្តឹងឧទ្ធរណ៍ទាំងពីរនេះ បានលើកឡើងអំពីបញ្ហាអង្គច្បាប់ និងអង្គហេតុស្រដៀងគ្នា ។

*ព័ត៌មានសាធារណៈ*

[6] ការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក, សេចក្តីណែនាំអនុវត្ត 01/2007/Rev.1 ចុះថ្ងៃទី០៥ តុលា ២០០៧, មាត្រា ៨.៤ [*បន្ទាប់ពីនេះទៅហៅថា៖* សេចក្តីណែនាំអនុវត្ត] ។ *ករណីរបស់ អៀង សារី,* សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធទៅនឹងការប្រាស្រ័យទាក់ទងគ្នារវាងជនត្រូវចោទនឹងប្រពន្ធរបស់គាត់, សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ-០៥) ចុះថ្ងៃទី៣០ មេសា ២០០៨, លេខERN 00184951-00184956, A104/II/7 កថាខណ្ឌទី ៨ ។

[7] *ករណីរបស់ អៀង សារី,* បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស ស្តីពី សិទ្ធិ និងកាតព្វកិច្ចរបស់ភាគី ទាក់ទងនឹងការបកប្រែ, សំណុំរឿងព្រហ្មទណ្ឌលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ-១២) ចុះថ្ងៃទី២២ កក្កដា ២០០៨ ។

៦. សហព្រះរាជអាជ្ញា ស្នើឲ្យ អង្គបុរេជំនុំជម្រះ ដាក់ចម្លើយតបនេះតាមការគួរទៅក្នុងវិបសាយរបស់ អ.វ.ត.ក ទន្ទឹមគ្នានឹងការដាក់ជូនឯកសារនានាដែលពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍នេះ ។ ការណ៍នេះគឺស្របទៅតាមវិធាន ៧៧.៦ នៃវិធានផ្ទៃក្នុង ដែលចែងថា អង្គបុរេជំនុំជម្រះអាចសម្រេចថា នីតិវិធីទាំងស្រុង ឬមួយផ្នែកនៃសវនាការ (ហើយបើតាមការពិចារណាទោះជាសេចក្តីសំអាង ឬជាសេចក្តីសម្រេចក៏ដោយ) ត្រូវធ្វើជាសាធារណៈ ។ ដើម្បីធ្វើដូច្នេះ អង្គបុរេជំនុំជម្រះ ត្រូវតែពិចារណាថា ការណ៍នេះដើម្បីជាប្រយោជន៍យុត្តិធម៌ និងមិនធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬវិធានការការពាររបស់តុលាការ[8] ។

៧. ការអនុវត្តន៍របស់ អង្គបុរេជំនុំជម្រះ បានឆ្លុះបញ្ចាំងស្របតាមស្មារតីនៃមាត្រា ៧៧.៦ នៅក្នុងសវនាការសាធារណៈរបស់ខ្លួន ការស្វែងរកជំនួយពីសំណាក់មិត្តរបស់តុលាការ (amici curiae) ការកាត់សេចក្តីជាសាធារណៈ ព្រមទាំងនៅក្នុងការដាក់សេចក្តីសំអាងហេតុរបស់ភាគីនានា និងសេចក្តីសម្រេចទាំងឡាយចូលទៅក្នុងវិបសាយរបស់ អ.វ.ត.ក ។

## ៣. ប្រវត្តិដំណើរការនីតិវិធីដែលពាក់ព័ន្ធ

៨. នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៨ ក្រុមមេធាវីការពារក្តីអន្តរជាតិរបស់ភាគីប្តឹងឧទ្ធរណ៍ បានជូនដំណឹងដល់ សហចៅក្រមស៊ើបអង្កេត ថាភាគីប្តឹងឧទ្ធរណ៍នឹងមិនឆ្លើយតបទៅនឹងសំណួររបស់អ្នកក្រោយនេះទេ រហូតទាល់តែគ្រប់ឯកសារទាំងអស់ ដែលបានភ្ជាប់ទៅនឹងដីកាសន្និដ្ឋានស្តាពរ ត្រូវបានបកប្រែជាភាសាបារាំងសិន[9] ។

៩. នៅគ្រានោះ នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៨ ក្នុងអំឡុងពេលសវនាការលើបណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងការឃុំខ្លួនបណ្តោះអាសន្ន ក្រុមមេធាវីការពារក្តីដដែលនេះបានស្វែងរកការពន្យារពេលដំណើរការនីតិវិធីមួយដោយគ្មានកំណត់ រហូតទាល់តែគ្រប់ឯកសារទាំងអស់នៅ

---

[8] វិធាន ៧៧.៦ នៃវិធានផ្ទៃក្នុង ។

[9] សេចក្តីសម្រេចទាក់ទងនឹងការបកប្រែ, ទំព័រទី ២ ។

ក្នុងសំណុំរឿងត្រូវបានបកប្រែឲ្យទៅជាភាសារបស់ក្រុមមេធាវីការពារក្តី គឺភាសាបារាំង[10] ។ នៅពេលធ្វើការពន្យារពេលសវនាការ អង្គបុរេជំនុំជម្រះ បានកត់សម្គាល់ថាការបដិសេធរបស់ក្រុមមេធាវីការពារក្តីមិនព្រមធ្វើសកម្មភាពបន្ត គឺជាការដកថយពីបណ្តឹងឧទ្ធរណ៍តាមគតិច្បាប់ ហើយមានអនុភាពដោយចំពោះផង និងអនុភាពជំទាស់នឹងសិទ្ធិជាមូលដ្ឋានរបស់ ខៀវ សំផន ក្នុងការមានអ្នកតំណាងផង[11] ។ អង្គបុរេជំនុំជម្រះ បានកត់សម្គាល់ថាវិធានផ្ទៃក្នុងបានទទួលស្គាល់ពីសេចក្តីត្រូវការនៃសហប្រតិបត្តិការរវាងក្រុមមេធាវីជាតិ និងអន្តរជាតិ ។ អង្គបុរេជំនុំជម្រះ បានកត់សម្គាល់ថា វិធាន ២១.១ នៃវិធានផ្ទៃក្នុង បានណែនាំឲ្យមានសហប្រតិបត្តិការនេះយ៉ាងមានប្រសិទ្ធិភាព ដោយតម្រូវឲ្យក្រុមមេធាវីការពារក្តីលើកឡើងពីបញ្ហាទាំងស្រុងផ្នែកភាសាវិទ្យានេះ ។ អង្គបុរេជំនុំជម្រះ បានសង្កេតឃើញថា អវត្តមាននៃសហប្រតិបត្តិការនេះ នាំឲ្យចុងចោទមានជម្រើសមួយដើម្បីជ្រើសរើសមេធាវីការពារក្តីថ្មីមួយឲ្យធ្វើជាអ្នកតំណាងរបស់គាត់[12] ។

១០. នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេត បានចេញសេចក្តីសម្រេចរបស់ខ្លួនមួយទាក់ទងនឹងការបកប្រែ ដើម្បីស្វែងរកសេចក្តីសម្រេចលើសំណើសុំឲ្យមានការបកប្រែទាំងឡាយដែលនៅមិនទាន់បានឆ្លើយតប ។ សេចក្តីសម្រេចទាក់ទងនឹងការបកប្រែ បានកត់សម្គាល់ថា កង្វះខាតនៅក្នុងបញ្ញត្តិច្បាប់ពាក់ព័ន្ធនឹងសិទ្ធិនៃការបកប្រែ និងបានដោះស្រាយបញ្ហាសិទ្ធិរបស់ចុងចោទទាក់ទងនឹងការបកប្រែក្នុងដំណាក់កាលនៃការជំនុំជម្រះមុនអង្គហេតុ នៅពេលដែលសហចៅក្រមស៊ើបអង្កេតជាប់រវល់ក្នុងដំណើរការស៊ើបសួរ ។ សេចក្តីសម្រេចនោះបានកត់សម្គាល់ថាអង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូង អាចនឹងចេញដីកា

---

[10] *ករណីរបស់ ខៀវ សំផន,* សេចក្តីសម្រេចលើសំណើសុំពន្យារពេលសវនាការលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន, សំណុំរឿងព្រហ្មទណ្ឌលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ-០៤) ចុះថ្ងៃទី២៣ មេសា ២០០៨, លេខERN 00180341-00180344, C26/I/25 កថាខណ្ឌទី ២ [*បន្ទាប់ពីនេះទៅហៅថា៖* សេចក្តីសម្រេចលើសំណើសុំពន្យារពេលសវនាការរបស់ ខៀវ សំផន] ។

[11] សេចក្តីសម្រេចលើសំណើសុំពន្យារពេលសវនាការរបស់ ខៀវ សំផន, កថាខណ្ឌទី ៩ ។

[12] សេចក្តីសម្រេចលើសំណើសុំពន្យារពេលសវនាការរបស់ ខៀវ សំផន, កថាខណ្ឌទី ១២ ។

សម្រេចបែបនេះបន្ថែមទៀត តាមដែលផលប្រយោជន៍យុត្តិធម៌ និងសិទ្ធិក្នុងការទទួលបាននូវការកាត់ក្តីដ៏ត្រឹមត្រូវអាចនឹងតម្រូវឱ្យធ្វើ[13] ។

១១. ក្នុងចំណោមនោះ សេចក្តីសម្រេចទាក់ទងនឹងការបកប្រែ បានចែងថាចុងចោទមានសិទ្ធិដើម្បីទទួលបាននូវភាសាមួយដែលខ្លួនយល់បាន (គ្រប់ករណីរបស់ចុងចោទទាំងអស់គឺ ភាសាខ្មែរ) លើឯកសារទាំងឡាយដូចតទៅ៖ ទី១) ដីកាបញ្ជូនរឿងទៅជំនុំជម្រះតាមវិធាន ៦៧.១, ទី២) ធាតុផ្សំនានានៃភស្តុតាង ដែលជាមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ, និងទី៣) ដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះនិងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាហើយកំណត់សម្គាល់ជើងទំព័រ និងលិបិក្រមនៃធាតុផ្សំអង្គហេតុ ដែលជាមូលដ្ឋាននៃដីកាទាំងនោះ ។ សេចក្តីសម្រេចទាក់ទងនឹងការបកប្រែនោះ បានកត់សម្គាល់ថា សេចក្តីសម្រេចទាំងឡាយរបស់ចៅក្រម និងការដាក់ឯកសាររបស់ភាគីនានា នឹងត្រូវបានផ្តល់ជូនបន្តទៀតជា ភាសាខ្មែរ និងយ៉ាងហោចណាស់ជាភាសាមួយផ្សេងទៀតតាមជម្រើសរបស់ចុងចោទ ដូចដែលសេចក្តីណែនាំអនុវត្តបានតម្រូវឱ្យធ្វើ[14] ។

១២. សេចក្តីសម្រេចទាក់ទងនឹងការបកប្រែ បានតម្រូវឱ្យភាគីនានាដោះស្រាយសេចក្តីត្រូវការបកប្រែ ដោយប្រើសមត្ថភាពផ្នែកភាសាវិទ្យានៅក្នុងក្រុមរបស់ខ្លួន និងពីខាងអង្គភាពគាំពារការការពារក្តី[15] ។ តាមការរៀបរាប់អំពីរបបគ្រប់គ្រងការបកប្រែបែបជឿនលឿនមួយ សេចក្តីសម្រេចនោះបានសុំឱ្យភាគីកាត់បន្ថយសេចក្តីត្រូវការបកប្រែ តាមរយៈការធ្វើឱ្យសមត្ថភាពផ្នែកភាសាវិទ្យារបស់ខ្លួនបានប្រសើរឡើង វាយតម្លៃនិងបញ្ជូនអាទិភាពទាំងនោះឱ្យទៅផ្នែកគ្រប់គ្រងតុលាការព្រមទាំងធ្វើសហប្រតិបត្តិការជាមួយនឹងផ្នែកគ្រប់គ្រងតុលាការ ដើម្បីឆ្ពោះទៅរកការយល់ស្របគ្នាមួយតាមដែលការគ្រប់គ្រងលើអាទិភាពទាំងនោះ បានតម្រូវឱ្យធ្វើ[16]

[13] សេចក្តីសម្រេចទាក់ទងនឹងការបកប្រែ, កថាខណ្ឌ E4 ។

[14] សេចក្តីសម្រេចទាក់ទងនឹងការបកប្រែ, កថាខណ្ឌ C3 ។

[15] សេចក្តីសម្រេចទាក់ទងនឹងការបកប្រែ, កថាខណ្ឌ A4 ។

[16] សេចក្តីសម្រេចទាក់ទងនឹងការបកប្រែ, កថាខណ្ឌ E2 ។

00221253



។ ដើម្បីឲ្យដំណើរការនៃសហប្រតិបត្តិការនេះ"ជាក់ស្តែង និងមានប្រសិទ្ធិភាព" សេចក្តីសម្រេចនោះបានចែងថាក្រុមមេធាវីការពារក្តីនីមួយៗមានសិទ្ធិទទួលបាននូវអ្នកបកប្រែ ដែលធ្វើការពេញម៉ោងដោយមិនគិតកម្រៃម្នាក់ ពីការិយាល័យរដ្ឋបាល[17] ។

១៣. ដោយមិនសុខចិត្តនឹងសេចក្តីសម្រេចទាក់ទងនឹងការបកប្រែ ភាគីប្តឹងឧទ្ធរណ៍បានសម្រេចដាក់បណ្តឹងឧទ្ធរណ៍នេះ ។ ដូចដែលបានកត់សម្គាល់ខាងលើស្រាប់ ភាគីប្តឹងឧទ្ធរណ៍ អះអាងថាសេចក្តីសម្រេចនោះ៖ ទី១) វាបំពានលើសិទ្ធិរបស់គាត់ ដោយមិនបានផ្តល់ឯកសារទាំងនោះជាភាសាបារាំង ដែលជាភាសារបស់មេធាវីការពារក្តីអន្តរជាតិរបស់គាត់, និងទី២) ការប្តូរបញ្ច្រាសដោយភ័ន្តច្រឡំនូវបន្ទុកក្នុងការបកប្រែឯកសារ ពីខាងតុលាការទៅឲ្យខាងមេធាវីការពារក្តី ។ ដូច្នេះ ដោយបានអះអាងអំពីការបំពានលើនីតិវិធី ខៀវ សំផន ស្វែងរកនូវការដោះលែងមួយពីការឃុំខ្លួនដោយគ្មានលក្ខខណ្ឌ[18] ។

## ៤. អំពីច្បាប់

*សិទ្ធិរបស់ចុងចោទ ទាក់ទងនឹងការបកប្រែឯកសារឲ្យទៅជាភាសារបស់ខ្លួន គឺមានកំរិត*

១៤. ឯកសារជាមូលដ្ឋានសម្រាប់តុលាការនេះ មិនបញ្ជាក់ឲ្យបានច្បាស់លាស់អំពីការបកប្រែឯកសារសម្រាប់ចុងចោទទេ ។ ទោះជាយ៉ាងនេះក៏ដោយ ឯកសារទាំងនោះពិតជាបានចែងអំពី "ការប្រើប្រាស់អ្នកបកប្រែ"[19] ។ សេចក្តីណែនាំអនុវត្ត ចែងអំពីការដាក់ឯកសារជាភាសាខ្មែរ(ជាភាសាដែលគ្រប់ជនត្រូវចោទទាំងអស់ពេលបច្ចុប្បន្ននេះយល់បាន) បន្ថែមដោយភាសាផ្លូវការមួយផ្សេងទៀត[20] ។ ដូចគ្នានេះដែរ ឯកសារមូលដ្ឋានរបស់តុលាការអន្តរជាតិស្រដៀងគ្នាផ្សេងៗទៀត ក៏មិនបានពណ៌នាឲ្យបានច្បាស់លាស់ពីវិសាលភាពនៃសិទ្ធិរបស់

---

[17] សេចក្តីសម្រេចទាក់ទងនឹងការបកប្រែ, កថាខណ្ឌ E3 ។

[18] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី ៧ ។

[19] ច្បាប់ អ.វ.ត.ក, មាត្រា ៣៥.ថ ។ វិធាន ៣០ នៃវិធានផ្ទៃក្នុង ។

[20] សេចក្តីណែនាំអនុវត្ត, មាត្រា ៧.១ និង ៧.២ ។

ចុងចោទទាក់ទងនឹងការបកប្រែដែរ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិ (“ICC”) បានបញ្ញត្តយ៉ាងច្បាស់លាស់ជាទីបំផុតអំពីសិទ្ធិរបស់ចុងចោទទាក់ទងនឹងការបកប្រែ ។ វាធានាអំពីជំនួយពីសំណាក់អ្នកបកប្រែដោយមិនគិតកម្រៃ ហើយការបកប្រែទាំងនេះ គឺចាំបាច់ត្រូវតែទៅតាមលក្ខខណ្ឌតម្រូវនៃយុត្តិធម៌ បើសិនជាមានដំណើរការនីតិវិធី ឬឯកសារណាមួយនៅក្នុងតុលាការមិនមានជាភាសាមួយដែលចុងចោទយល់ ឬនិយាយមិនបានទាំងស្រុង[21] ។ តុលាការសិទ្ធិមនុស្សអឺរ៉ុប (“ECHR”) បានតម្រូវឲ្យមានការបកប្រែផ្ទាល់មាត់ ឬបកប្រែសរសេរនូវគ្រប់ឯកសារទាំងអស់ដែលចាំបាច់សម្រាប់ចុងចោទយល់បាន ដើម្បីជាប្រយោជន៍ដល់ការកាត់ក្តីដ៏ត្រឹមត្រូវមួយ[22] ។ តុលាការដទៃទៀត បានសម្រេចថា សិទ្ធិទាក់ទងនឹងការបកប្រែផ្ទាល់មាត់ គ្របដណ្តប់លើសិទ្ធិទាក់ទងនឹងការបកប្រែសរសេរនៃឯកសារជាក់លាក់មួយចំនួន[23] ។

១៥. អង្គការយុត្តិធម៌អន្តរជាតិនានាបានពិចារណាអំពីសិទ្ធិទាក់ទងនឹងការបកប្រែតាមមធ្យោបាយ បីយ៉ាងធំៗ ។ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (“HRC”) បានមើល ឃើញសិទ្ធិទាំងនោះ ពីខាងទស្សនៈនៃការផ្តល់នូវធាតុបករណ៍

[21] លក្ខន្តិកៈទីក្រុងរ៉ូមសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ, មាត្រា ៥១.១.គ, ៦៧.១.ច [*បន្ទាប់ពីនេះទៅហៅថា៖* លក្ខន្តិកៈទីក្រុងរ៉ូម]។ តុលាការព្រហ្មទណ្ឌអន្តរជាតិ, វិធាននៃនីតិវិធី និងភស្តុតាង, វិធាន ៤២ ៧៦.៣ ១៨៧ ២០៣ [*បន្ទាប់ពីនេះទៅហៅថា៖* វិធានសម្រាប់តុលាការ ICC] ។

[22] *Leudicke ទល់នឹង ប្រទេសអាល្លឺម៉ង់,* ពាក្យសុំលេខ ៦២១០/៧៣ ៦៨៧៧/៧៥ ៧១៣២/៧៥, សេចក្តីសម្រេច ចុះថ្ងៃទី២៨ វិច្ឆិកា ១៩៧៨, កថាខណ្ឌទី ៤៨ [*បន្ទាប់ពីនេះទៅហៅថា៖* សេចក្តីសម្រេចលើករណីរបស់ Leudicke] ។ *Kamasinski ទល់នឹង ប្រទេសអូទ្រីស,* ពាក្យសុំលេខ ៩៧៨៣/៨២, សេចក្តីសម្រេច ចុះថ្ងៃទី១៩ ធ្នូ ១៩៨៩, កថាខណ្ឌទី ៤៨ [*បន្ទាប់ពីនេះទៅហៅថា៖* សេចក្តីសម្រេចលើករណីរបស់ Kamasinski] ។

[23] លក្ខន្តិកៈសម្រាប់តុលាការ ICTR, មាត្រា ២០.៤.ច ។ ECHR, មាត្រា ៦.៣.ង ។ ច្បាប់ អ.វ.ត.ក, មាត្រា ៣៥.ច ។ *រដ្ឋអាជ្ញា ទល់នឹង Muhimana,* សំណុំរឿងលេខ ICTR-95-I-B-I, សេចក្តីសម្រេចលើញត្តិស្នើសុំរបស់មេធាវីការពារក្តី ស្តីពីការបកប្រែឯកសារដាក់បន្ទុក និងឯកសារនីតិវិធី ទៅជាភាសា Kinyarwanda, ចុះថ្ងៃទី០៦ វិច្ឆិកា ២០០១, កថាខណ្ឌទី ១៦ [*បន្ទាប់ពីនេះទៅហៅថា៖* សេចក្តីសម្រេចលើករណីរបស់ Muhimana] ។ សេចក្តីសម្រេចលើករណីរបស់ Leudicke ។ កថាខណ្ឌទី ៧៤ ។

សម្រាប់ការត្រៀមរៀបចំ កិច្ចការពារក្តី[24] ។ តុលាការ*ពិសេស (ad hoc tribunals)* បានមើលឃើញសិទ្ធិទាំងនោះ ថាជាតុល្យភាពមួយរវាងផលប្រយោជន៍របស់ចុងចោទ ក្នុងការទទួលបាននូវឯកសារដែល បានបកប្រែរួចស្រេច ហើយសិទ្ធិរបស់គាត់នឹងត្រូវបានធ្វើការជំនុំជម្រះដោយគ្មានការពន្យារពេលមិនសមហេតុផលឡើយ ដោយសារយល់ឃើញថាសេចក្តីត្រូវការបកប្រែមានកាន់តែច្រើនឡើងនោះ ល្បឿននៃដំណើរការនីតិវិធីក៏កាន់តែយឺតទៅៗដែរ[25]។ តុលាការ ICC និង ECHR បានសម្រេចថាគេត្រូវតែផ្តល់នូវការបកប្រែបែបដូច្នោះ ដើម្បី"ធានាដល់ចុងចោទឱ្យបានយល់ដឹងអំពីករណីប្រឆាំងនឹងរូបខ្លួន ហើយដើម្បីការពារខ្លួនគាត់"[26] ។

១៦. សិទ្ធិរបស់ចុងចោទទាក់ទងនឹងការបកប្រែ មិនពន្លាតទៅដល់គ្រប់ឯកសារទាំងអស់ ដែលមាននៅក្នុងសំណុំរឿងទេ[27] ។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីត ប្រទេសយូហ្គោស្លាវី ("ICTY") និងប្រទេសរវ៉ាន់ដា ("ICTR") បានបដិសេធសំណើសុំឱ្យមានការបកប្រែគ្រប់ឯកសារទាំងអស់ ដោយផ្អែកលើមូលដ្ឋានមួយថា ការបកប្រែឯកសារជាមុនឱ្យទៅជាភាសារបស់ចុងចោទដែលហួសពីតម្រូវការនោះ នឹងនាំឱ្យអន្តរាយដល់សិទ្ធិរបស់ចុងចោទ ក្នុងការ

---

[24] *Harward ទល់នឹង ប្រទេសន័រវេ,* សេចក្តីប្រកាសលេខ ៤៥១/១៩៩១, ឯកសាររបស់ អ.ស.ប CCPR/C/51/D/451/1991, គណៈកម្មាធិការសិទ្ធិមនុស្ស, ចុះថ្ងៃទី១៦ សីហា ១៩៩៤, កថាខណ្ឌទី ៩.៤ [*បន្ទាប់ពីនេះទៅហៅថា៖* សេចក្តីសម្រេចលើករណីរបស់ Harward] ។

[25] *រដ្ឋអាជ្ញា ទល់នឹង Seselj,* សំណុំរឿងលេខ IT-03-67-PT, សេចក្តីសម្រេចស្តីពីការបកប្រែ, ចុះថ្ងៃទី០៦ មីនា ២០០៣, ទំព័រទី ១ [*បន្ទាប់ពីនេះទៅហៅថា៖* សេចក្តីសម្រេចលើករណីរបស់ Seselj] ។ សេចក្តីសម្រេចលើករណីរបស់ Muhimana, កថាខណ្ឌទី ១២ ។ *រដ្ឋអាជ្ញា ទល់នឹង Ljubicic,* សំណុំរឿងលេខ IT-00-41-PT, សេចក្តីសម្រេចលើសំណើរបស់ក្រុម មេធាវីការពារក្តីស្តីពីការបកប្រែគ្រប់ឯកសារទាំងអស់, ចុះថ្ងៃទី២០ វិច្ឆិកា ២០០២, ទំព័រទី ៣ [*បន្ទាប់ពីនេះទៅហៅថា៖* សេចក្តីសម្រេចលើករណីរបស់ Ljubicic] ។

[26] *រដ្ឋអាជ្ញា ទល់នឹង Lubanga,* សំណុំរឿងលេខ ICC-01/04-01/06, សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី ថ្ងៃទី០៣ និង ០៤ កក្កដា ២០០៦, ចុះថ្ងៃទី០៤ សីហា ២០០៦ [*បន្ទាប់ពីនេះទៅហៅថា៖* សេចក្តីសម្រេចលើករណីរបស់ Lubanga] ។

[27] សេចក្តីសម្រេចលើករណីរបស់ Harward, កថាខណ្ឌទី ៩.៥ ។ *រដ្ឋអាជ្ញា ទល់នឹង Katanga,* សំណុំរឿងលេខ ICC-01/04-01/07, សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីរបស់ Mathieu Ngudjolo Chui ពាក់ព័ន្ធនឹងការបកប្រែឯកសារ ៣, ៥ ចុះថ្ងៃទី ១៥ ឧសភា ២០០៨ [*បន្ទាប់ពីនេះទៅហៅថា៖* សេចក្តីសម្រេចលើករណីរបស់ Katanga] ។ *រដ្ឋអាជ្ញា ទល់នឹង Chui,* សំណុំរឿងលេខ ICC-01/04-02/07, សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី ពាក់ព័ន្ធនឹងការកំណត់ពេលវេលា, ថ្ងៃទី២៧ កុម្ភៈ ២០០៨ ទំព័រទី ៤ [*បន្ទាប់ពីនេះទៅហៅថា៖* សេចក្តីសម្រេចលើករណីរបស់ Chui] ។ សេចក្តីសម្រេចលើករណីរបស់ Muhimana, កថាខណ្ឌទី២៥។

ទទួលបាននូវការកាត់ក្តីមួយដ៏ឆាប់រហ័ស ដោយសារតែមានតម្រូវការខាងពេលវេលា និងធនធានយ៉ាងច្រើន[28] ។ តុលាការ ICC បានសម្រេចថា គោលការណ៍នៃភាពត្រឹមត្រូវយុត្តិធម៌ មិនផ្តល់ដល់ចុងចោទនូវសិទ្ធិទទួលបានការបកប្រែគ្រប់ឯកសារនីតិវិធី និងឯកសារជាភស្តុតាងទាំងអស់នោះទេ[29] ។ តុលាការ ICTY បានបដិសេធ ចំពោះការបកប្រែគ្រប់ឯកសារទាំងអស់ ទោះបីជាការធ្វើស្វ័យតំណាងដោយចុងចោទខ្លួនឯងក៏ដោយ[30] ។

១៧. ការផ្តល់ឲ្យចុងចោទនូវអ្នកបកប្រែផ្ទាល់មាត់ម្នាក់ គឺជាការជំនួសដ៏គ្រប់គ្រាន់មួយ សំរាប់ការផ្តល់ជូននូវឯកសារជាក់លាក់នានា តាមភាសាដែលគាត់យល់បាន[31] ។ តុលាការ ICTY និយាយថាប្រសិនបើអ្នកគ្រប់គ្រងបញ្ជីរបស់ខ្លួនរកឃើញថាមានការលំបាកនៅក្នុងការបកប្រែសរសេរចំពោះឯកសារជាក់លាក់មួយចំនួនទៅជាភាសារបស់ចុងចោទ នោះអ្នកគ្រប់គ្រងបញ្ជីអាចធ្វើការបកប្រែផ្ទាល់មាត់ទៅលើឯកសារទាំងនោះ "ដើម្បីឲ្យ [ចុងចោទ] មានលទ្ធភាពទទួលបាននូវចំណុចសំខាន់ៗនៃខ្លឹមសាររបស់វា"[32] ។ តុលាការ ICC ផ្តល់ឲ្យចុងចោទនូវអ្នកបកប្រែផ្ទាល់មាត់ម្នាក់ ជំនួសការផ្តល់ឲ្យចុងចោទនូវការបកប្រែសរសេរនូវឯកសារនានាហួសពីអ្វីដែលបានតម្រូវដោយលិខិតុបករណ៍របស់ខ្លួន ។

*ប្រភេទនៃឯកសារដែលតម្រូវឲ្យមានការបកប្រែទៅជាភាសារបស់ចុងចោទ*

១៨. វិធាន ៦៧ តម្រូវថា ចុងចោទត្រូវទទួលបានជាបន្ទាន់នូវដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) មួយច្បាប់ដែលត្រូវផ្តល់ជូនដោយសហចៅក្រមស៊ើបអង្កេត ។ ទោះជាយ៉ាងដូច្នេះក៏ដោយ បញ្ញត្តិនេះមិនបានបញ្ជាក់ឲ្យបានច្បាស់លាស់អំពីការផ្តល់ដល់ចុងចោទ នូវសិទ្ធិទទួលបានដីកាបញ្ជូនរឿងទៅជំនុំជម្រះតាមភាសាមួយដែលគាត់យល់បាននោះទេ ។ តុលាការ

[28] សេចក្តីសម្រេចលើករណីរបស់ Seselj, ទំព័រទី ១ ។ សេចក្តីសម្រេចលើករណីរបស់ Muhimana, កថាខណ្ឌទី ១២ ។

[29] សេចក្តីសម្រេចលើករណីរបស់ Lubanga, ទំព័រទី ៥-៦ ។ សេចក្តីសម្រេចលើករណីរបស់ Katanga, ទំព័រទី ៦ ។

[30] សេចក្តីសម្រេចលើករណីរបស់ Seselj, ទំព័រទី ១ ។

[31] សេចក្តីសម្រេចលើករណីរបស់ Harward, កថាខណ្ឌទី ៩.៥ ។

[32] សេចក្តីសម្រេចលើករណីរបស់ Muhimana, កថាខណ្ឌទី ៣០ ។

អន្តរជាតិដែលសឹងតែគ្មានការលើកលែងអ្វីទាំងអស់ ផ្តល់ឱ្យចុងចោទនូវដីកាបញ្ជូនរឿងទៅជំនុំជម្រះជាភាសាមួយដែលគេយល់បាន ទោះបីជាយុត្តិសាស្ត្រស្តីពីការបកប្រែឯកសារគាំទ្រចំពោះដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនស៊ីសង្វាក់គ្នាក៏ដោយ[33]។ តុលាការ ICTY និង ICTR ផ្តល់នូវឯកសារដូចនេះជាភាសារបស់ចុងចោទ គឺដោយសារតែបញ្ហាសិទ្ធិ[34]។ សិទ្ធិនេះអនុវត្តផងដែរចំពោះគ្រប់ឯកសារគាំទ្រទាំងអស់ ដោយមិនគិតថាតើឯកសារនោះបានបង្ហាញនៅក្នុងពេលជំនុំជម្រះនោះឡើយ[35] ។ ទោះជាយ៉ាងដូច្នេះក៏ដោយ តុលាការ ICC ផ្តល់ឱ្យមានការបកប្រែឱ្យទៅជាភាសារបស់ចុងចោទ តែបញ្ជីភស្តុតាងដែលគាំទ្រចំពោះដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ។ នៅក្នុងករណីរបស់ *Lubanga,* តុលាការ ICC បានសម្រេចថា ការបកប្រែសេចក្តីរៀបរាប់ពិស្តារនៃបទចោទ ជាមួយនឹងបញ្ជីភស្តុតាង គឺជាការជូនដំណឹងដល់ចុងចោទយ៉ាងគ្រប់គ្រាន់ហើយ អំពីប្រភេទ បុព្វហេតុ និងខ្លឹមសារនៃបទចោទ ប្រឆាំងនឹងជននោះ[36] ។ អាស្រ័យហេតុនេះ តុលាការ ICC បានច្រានចោលពាក្យសុំរបស់ចុងចោទ ដែលស្នើសុំឯកសារគាំទ្រដីកាបញ្ជូនរឿងទៅជំនុំជម្រះជាភាសារបស់ខ្លួន ប៉ុន្តែបានជំនួសមកវិញដោយបានផ្តល់ឱ្យគាត់ នូវការប្រើប្រាស់អ្នកបកប្រែផ្ទាល់មាត់ម្នាក់ជាអចិន្ត្រៃយ៍[37] ។

១៩. ជាការបន្ថែមចំពោះដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងឯកសារគាំទ្ររបស់ដីកានេះ តុលាការអន្តរជាតិ បានសម្រេចថា វត្ថុតាងឯកសារផ្សេងៗខុសៗគ្នា ត្រូវតែដាក់បង្ហាញដល់ចុងចោទតាមភាសារបស់គេ ។ សេចក្តីរៀបរាប់នៃឯកសារទាំងអស់នេះ គឺខុសៗគ្នា ។ ឧទាហរណ៍ តុលាការ*ពិសេស* បានតម្រូវថា ឯកសារផ្សេងៗដែលបានបង្ហាញដូចខាងក្រោម ត្រូវតែបកប្រែទៅជាភាសាដែលចុងចោទយល់បាន៖ ទី១) កំណត់ហេតុសាក្សីដែលអយ្យការមានបំណង

---

[33] វិធាន ៤៧.ឆ នៃវិធានសម្រាប់តុលាការ ICTY ។ វិធាន ៤៧.ឆ នៃវិធានសម្រាប់តុលាការ ICTR ។

[34] វិធាន ៦៦.ក នៃវិធានសម្រាប់តុលាការ ICTY ។ វិធាន ៦៦.ក នៃវិធានសម្រាប់តុលាការ ICTR ។

[35] សេចក្តីសម្រេចលើករណីរបស់ Seselj, ទំព័រទី ១ ។ សេចក្តីសម្រេចករណីរបស់ Ljubicic, ទំព័រទី ៣ ។ សេចក្តីសម្រេចលើករណីរបស់ Muhimana, កថាខណ្ឌទី ២៣ ។

[36] វិធាន ១២១.៣ នៃវិធានសម្រាប់តុលាការ ICC ។

[37] សេចក្តីសម្រេចលើករណីរបស់ Lubanga, ទំព័រទី ៧ ។

យកមកបង្ហាញនៅក្នុងសវនាការជំនុំជម្រះក្តី[38], ទី២) ភស្តុតាងនានាដែលនឹងត្រូវយកមកបង្ហាញនៅក្នុងការជំនុំជម្រះក្តី[39], ទី៣) ភស្តុតាងដោះបន្ទុកស្ថិតនៅក្រោមការកាន់កាប់ និងចំណេះដឹងរបស់អយ្យការ[40] ។ តុលាការ ICTY បានកំណត់ថា ក្រៅអំពីភស្តុតាងគាំទ្រទៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ អយ្យការត្រូវបកប្រែឯកសារទាំងឡាយ ដែលបង្កើតបានជាទម្រង់ជាមូលដ្ឋាននៃការកំណត់អំពីបទចោទប្រកាន់ប្រឆាំងនឹងចុងចោទ[41] ។ តុលាការបានផ្តល់យុត្តិកម្មសំរាប់ការដាក់កម្រិតនេះថា លិខិតុបករណ៍របស់ខ្លួនមិនផ្តល់សិទ្ធិដល់ចុងចោទថាត្រូវតែទទួលបានឯកសារ *ទាំងអស់* ជាភាសាដែលខ្លួនយល់នោះឡើយ ប៉ុន្តែមានតែឯកសារទាំងឡាយណាដែលនឹងកំណត់អំពីពិរុទ្ធភាព និងភាពគ្មានទោសរបស់ចុងចោទនៅក្នុងពេលជំនុំជម្រះក្តីតែប៉ុណ្ណោះ ដែលអាចផ្តល់ជូន[42] ។ ទោះជាយ៉ាងនេះក្តី តុលាការ ICC មិនព្រមផ្តល់នូវការបកប្រែលើភស្តុតាងសំរាប់ដោះបន្ទុកទេ[43] ។ តុលាការ ICC ក៏បានកំណត់ផងដែរថា អយ្យការមិនតម្រូវឱ្យបកប្រែគ្រប់ឯកសារទាំងអស់ដែលខ្លួនជាប់កាតព្វកិច្ចត្រូវដាក់បង្ហាញដល់មេធាវីការពារក្តីនោះទេ[44] ។ វាបានចង្អុលបង្ហាញថា វត្ថុតាងឯកសារដែលបានបញ្ជាក់យ៉ាងច្បាស់ ដែលអយ្យការត្រូវតែបកប្រែនោះ គឺកំណត់ហេតុសាក្សីដាក់បន្ទុកនានាតែប៉ុណ្ណោះ [45] ។

*តើអ្នកណាជាអ្នកត្រូវទទួលបន្ទុកនៃការបកប្រែឯកសារនានា?*

---

[38] សេចក្តីសម្រេចលើករណីរបស់ Muhimana, កថាខណ្ឌទី ២៣ ។ វិធាន ៦៦.ក.២ នៃវិធានសម្រាប់តុលាការ ICTY ។ សេចក្តីសម្រេចលើករណីរបស់ Seselj, ទំព័រទី ១ ។ សេចក្តីសម្រេចលើករណីរបស់ Ljubicic, ទំព័រទី ១ ។

[39] សេចក្តីសម្រេចលើករណីរបស់ Muhimana, កថាខណ្ឌទី ២៥ ។

[40] សេចក្តីសម្រេចលើករណីរបស់ Ljubicic, ទំព័រទី ៣ ។

[41] សេចក្តីសម្រេចលើករណីរបស់ Naletilic, ទំព័រទី ៣ (សេចក្តីសម្រេចទាក់ទងនឹងការបកប្រែ, កំណត់សំគាល់ជើងទំព័រ ទី១៤) ។

[42] សេចក្តីសម្រេចលើករណីរបស់ Delalic, កថាខណ្ឌទី ៨ (សេចក្តីសម្រេចទាក់ទងនឹងការបកប្រែ, កំណត់សំគាល់ជើងទំព័រ ទី៧) ។

[43] សេចក្តីសម្រេចលើករណីរបស់ Lubanga, ទំព័រទី ៥-៨ ។

[44] សេចក្តីសម្រេចលើករណីរបស់ Lubanga, ទំព័រទី ៧ ។

[45] សេចក្តីសម្រេចលើករណីរបស់ Chui, ទំព័រទី ៤ (ដែលយោងវិធាន ៧៦.៣ នៃវិធានសម្រាប់តុលាការ ICC) ។

២០. លិខិតុបករណ៍របស់អង្គជំនុំជម្រះនេះ មិនបានធ្វើប្រតិភូកម្មតួនាទីនៃការបកប្រែឲ្យបានច្បាស់លាស់ទៅឲ្យអង្គភាពជាក់លាក់ណាមួយទេ ។ ទោះបីសេចក្តីណែនាំអនុវត្ត ដាក់ការទទួលខុសត្រូវនៃការបកប្រែសេចក្តីសំអាងជាក់លាក់នានាទៅលើផ្នែកគ្រប់គ្រងតុលាការ ក៏ដោយ ក៏ប៉ុន្តែគ្មានការធ្វើប្រតិភូកម្មច្បាស់លាស់ ចំពោះការងារបកប្រែឯកសារប្រភេទផ្សេងៗទៀតនោះទេ ជាពិសេស ចំពោះឯកសារជាភស្តុតាង[46] ។

២១. តុលាការ ICTR បានតម្រូវឲ្យអ្នកកាន់បញ្ជីរបស់ខ្លួន ធ្វើការបកប្រែឯកសារទាំងឡាយណាដែលគេបានរកឃើញថា ចាំបាច់ត្រូវផ្តល់ឲ្យចុងចោទ ជាភាសារបស់គេតែប៉ុណ្ណោះ[47] ។ ផ្ទុយមកវិញ នៅចំពោះមុខតុលាការ ICC លើកលែងតែឯកសារទាំងឡាយដែលបានដាក់លក្ខខណ្ឌតម្រូវដល់អយ្យការត្រូវផ្តល់ឲ្យចុងចោទជាភាសារបស់គេ ក្រុមមេធាវីការពារក្តីត្រូវទទួលខុសត្រូវក្នុងការរៀបចំធនធានរបស់ខ្លួនដើម្បីការពារសិទ្ធិរបស់ចុងចោទ[48] ។

*មិនមានសិទ្ធិបកប្រែឯកសារនានាឲ្យទៅជាភាសារបស់មេធាវីការពារក្តីទេ*

២២. សូម្បីលិខិតុបករណ៍របស់អង្គជំនុំជម្រះនេះ និងរបស់តុលាការអន្តរជាតិស្រដៀងគ្នាដទៃទៀត ក៏មិនមានបទប្បញ្ញត្តិណាមួយ ដែលចែងអំពីសិទ្ធិរបស់ក្រុមមេធាវីការពារក្តី ទាក់ទងនឹងការបកប្រែឯកសារនោះដែរ ។ ក្នុងករណី *Muhimana*, តុលាការ ICTR បានធ្វើការពិចារណាថាតើមេធាវីការពារក្តីម្នាក់ ដែលជាមនុស្សអភិរក្សភាសាបារាំង មានសិទ្ធិទទួលបានឯកសារទាំងអស់ ដែលបានបង្ហាញដោយអយ្យការជាភាសាបារាំងដែរឬទេ និងដើម្បីឲ្យអ្នកកាន់បញ្ជីធានាលើការបកប្រែដោយសេរី លើគ្រប់ឯកសារជាលាយលក្ខណ៍អក្សរទាំងនោះ ។ តុលាការនេះបានតម្រូវថា ឯកសារចំនួនពីរប្រភេទ គួរតែបានបកប្រែទៅជាភាសាផ្លូវការទាំងពីរ៖ ទី១) សារណារបស់គូភាគី និង ទី២) ភស្តុតាងដែលយកជាសំអាងនៅពេលសវនាការជំនុំ

---

[46] សេចក្តីណែនាំអនុវត្ត, មាត្រា ៧.២ ។

[47] សេចក្តីសម្រេចលើករណីរបស់ Muhimana, កថាខណ្ឌទី ១០, ១៣ ។

[48] សេចក្តីសម្រេចលើករណីរបស់ Chui, ទំព័រទី ៥ ។ សេចក្តីសម្រេចលើករណីរបស់ Katanga, ទំព័រទី ៣, ៦ ។

ជម្រះ[49] ។ នៅក្នុងករណីនោះ ទោះបីមានមេធាវីការពារក្តីតែម្នាក់ នៅក្នុងចំណោមមេធាវីទាំងនោះចេះនិយាយ និងយល់បានតែភាសាបារាំងក៏ដោយ ក៏ប៉ុន្តែមេធាវីម្នាក់ផ្សេងទៀតចេះនិយាយទាំងភាសាបារាំង និងភាសាអង់គ្លេស[50] ។ តុលាការបានកំណត់ថា លទ្ធភាពក្នុងការបកប្រែរបស់ក្រុមមេធាវីការពារក្តីម្នាក់ មិនបានជួយសម្រាលដល់កាតព្វកិច្ចរបស់តុលាការដើម្បីបកប្រែសេចក្តីសម្រេច សារណាជាលាយលក្ខណ៍អក្សរ និងភស្តុតាងនានាទេ[51] ។ យ៉ាងណាក៏ដោយ គេមានការសង្ឃឹមថា "តាមរយៈកិច្ចសហការប្រកបដោយផ្លែផ្កា" មេធាវីម្នាក់អាចជួយមេធាវីម្នាក់ផ្សេងទៀត "ឱ្យយល់អំពីខ្លឹមសារនៃឯកសារនានាបាន"[52] ។

២៣. នៅក្នុងករណី *Lubanga,* ចុងចោទបានស្នើសុំឱ្យមានការបកប្រែឯកសារនានា ដែលបានដាក់បង្ហាញដោយអយ្យការទៅជាភាសាបារាំង ដែលជាភាសាផ្លូវការមួយរបស់តុលាការ ICC ដែលគាត់យល់បាន[53] ។ នៅក្នុងសេចក្តីសម្រេចដែលធ្វើការបដិសេធលើសំណើនេះ តុលាការ ICC បានពិចារណាថា ទោះបីមេធាវីការពារក្តីរបស់ចុងចោទត្រូវបានគេដាក់លក្ខខណ្ឌតម្រូវថាត្រូវតែចេះភាសាមួយនៃភាសាផ្លូវការរបស់តុលាការឱ្យបានស្ទាត់ជំនាញក៏ដោយ ក៏គាត់បានដាក់ញត្តិស្នើសុំទាំងពីរភាសា គឺភាសាបារាំង និងភាសាអង់គ្លេស[54] ។ ស្រដៀងគ្នានេះដែរ នៅក្នុងករណី *Ljubicic,* តុលាការ ICTY បានសម្រេចថា ទោះបីចុងចោទមិនអាចយល់បានលើឯកសារទាំងអស់នៅក្នុងករណីនោះក៏ដោយ ក៏ "យ៉ាងហោចណាស់ក៏មានមេធាវីម្នាក់ក្នុងចំណោមមេធាវីរបស់គាត់ត្រូវបានគេសន្មតថា បានចេះយ៉ាងស្ទាត់ជំនាញនៅលើភាសាមួយក្នុងចំណោមភាសាផ្លូវការនានារបស់តុលាការ ហើយគួរតែមានសមត្ថភាពចូលរួមយ៉ាងពេញលេញនៅក្នុងដំណើរការនីតិវិធី[55] ។

---

[49] សេចក្តីសម្រេចលើករណីរបស់ Muhimana, កថាខណ្ឌទី ៣២-៣៣ ។

[50] សេចក្តីសម្រេចលើករណីរបស់ Muhimana, កថាខណ្ឌទី ៣១ ។

[51] សេចក្តីសម្រេចលើករណីរបស់ Muhimana, កថាខណ្ឌទី ៣២-៣៣ ។

[52] សេចក្តីសម្រេចលើករណីរបស់ Muhimana, កថាខណ្ឌទី ៣៣ ។

[53] សេចក្តីសម្រេចលើករណីរបស់ Lubanga, ទំព័រទី ២, ៤ ។

[54] សេចក្តីសម្រេចលើករណីរបស់ Lubanga, ទំព័រទី ៤ ។

[55] សេចក្តីសម្រេចលើករណីរបស់ Ljubicic, ទំព័រទី ៣ ។

*តម្រូវការនៃកិច្ចសហការរវាងមេធាវីការពារក្តី ដើម្បីដោះស្រាយលើការលំបាកខាងផ្នែកភាសា*

២៤. វិធាន ២២.១ ចែងថា ចុងចោទទាំងអស់នៅចំពោះមុខតុលាការនេះ ត្រូវមានសិទ្ធិទទួលបានជំនួយពីមេធាវីជាតិ ឬអន្តរជាតិ "ដោយសហការជាមួយ" មេធាវីជាតិ ។

២៥. នៅក្នុងករណីរបស់ *Muhimana,* ដូចបានលើកឡើងខាងលើ តុលាការ ICTR បានពិចារណាពីលទ្ធភាព របស់មេធាវីម្នាក់ក្នុងការយល់ដឹងអំពីភាសាទាំងពីរ៖ ភាសាបារាំង និងភាសាអង់គ្លេស ដែលពាក់ព័ន្ធនឹងសេចក្តីសម្រេចរបស់ខ្លួន ចំពោះអ្វីដែលមាននៅក្នុងការបកប្រែជាភាសាបារាំង ដើម្បីផ្តល់ជូនមេធាវីការពារក្តីម្នាក់ផ្សេងទៀត ។ តុលាការនេះ បានលើកទឹកចិត្តឲ្យមេធាវីការពារក្តីសហការគ្នាដើម្បីបានយល់ទៅលើឯកសារនានា ហួសពីមូលដ្ឋានដែលបានកំណត់នៅក្នុងការងារបកប្រែ ។ នៅក្នុងករណី *ខៀវ សំផន* អង្គបុរេជំនុំជម្រះនេះ បានជូនយោបល់ថា ប្រសិនបើមេធាវីអន្តរជាតិរបស់ចុងចោទរូបនេះមិនអាចធ្វើការងារជាមួយ សហមេធាវីកម្ពុជារបស់ខ្លួននៅលើបញ្ហានៃការបកប្រែបានទេ នោះដំណោះស្រាយរបស់ចុងចោទគឺជាលទ្ធភាពរបស់គាត់ក្នុងការជ្រើសរើសមេធាវីការពារក្តីអន្តរជាតិម្នាក់ផ្សេងបាន[56] ។

## ៥. សេចក្តីសំអាង

*បណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបានទេ*

២៦. វិធាន ៧៤.៣ បានរៀបរាប់ទាំងអស់នូវប្រភេទដីកាដែលជនត្រូវចោទអាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងបាន ទៅអង្គបុរេជំនុំជម្រះ ។ វិធាននេះ មិនបានគិតទុកជាមុនអំពីបណ្តឹងឧទ្ធរណ៍ណាមួយ ប្រឆាំងនឹងដីកាណាមួយដែលបដិសេធសំណើសុំការបកប្រែឯកសារ ទៅជាភាសារបស់ជនត្រូវចោទ ឬរបស់មេធាវីការពារក្តីរបស់ខ្លួននោះឡើយ ។ ហេតុដូច្នេះ បណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទមិនអាចទទួលយកបានទេ និងគួរតែត្រូវបដិសេធចោល ។

---

[56] សេចក្តីសម្រេចលើសំណើសុំពន្យារពេលសវនាការរបស់ ខៀវ សំផន, កថាខណ្ឌទី ១២ ។

២៧. ចរិតលក្ខណៈដែលរៀបរាប់ទាំងអស់នៃវិធាន ៧៤.៣ នេះ ត្រូវបានលើកយកមកបង្ហាញដូចខាងក្រោម ៖

i. ការអានជាធម្មតានៅលើ ផ្នែក ឃ នៃវិធាននេះបង្ហាញឱ្យឃើញថា យុត្តាធិការដ៏ចំបងរបស់អង្គបុរេជំនុំជម្រះ គឺដើម្បីកាត់សេចក្តីវិវាទរវាងសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត[57] ។ កិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក បានគិតទុកជាមុននៅលើបញ្ហានេះថាជា មុខងារតែមួយគត់របស់អង្គបុរេជំនុំជម្រះ[58] ។ វិធាន ៧៣ មានចែងអំពី "យុត្តាធិការបន្ថែម" របស់អង្គបុរេជំនុំជម្រះ និងបញ្ជាក់យ៉ាងច្បាស់ក្នុងការកម្រិតឱ្យនៅត្រឹមតែអ្វីៗដែលមានចែងនៅក្នុងនោះតែប៉ុណ្ណោះ ។

ii. ចំណងជើងនៃវិធាន ៧៤ *មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍* គឺបានពន្យល់ខ្លួនឯងរួចស្រេចហើយ ដែលវាបង្ហាញឱ្យឃើញថា មានតែដីកាដែលបានរៀបរាប់នៅក្នុងវិធាននេះតែប៉ុណ្ណោះដែលអាចប្តឹងឧទ្ធរណ៍ចំពោះមុខអង្គបុរេជំនុំជម្រះ ។ ដូចដែលវាអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាអាចប្តឹងឧទ្ធរណ៍បានលើ *គ្រប់* ដីកាទាំងអស់របស់សហចៅក្រមស៊ើបអង្កេត ប៉ុន្តែវាដាក់កម្រិតទៅលើសិទ្ធិប្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ បានចំពោះតែដីកាទាំងឡាយដែលមានចែងនៅក្នុងវិធាន ៧៤.៣ តែប៉ុណ្ណោះ ។

iii. វិធាននេះ មិនបានផ្តល់យុត្តាធិការដែលសេសសល់ណាមួយសំរាប់អង្គបុរេជំនុំជម្រះ ដែលនៅក្នុងនោះមិនបានផ្តល់អំណាចចម្រុះ (ដូចជាតុលាការកំពូលថ្នាក់ជាតិ) ដល់អង្គជំនុំជម្រះនេះ ដើម្បីបើកសវនាការលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចណាមួយរបស់សហចៅក្រមស៊ើបអង្កេតដែលពុំមានការពេញចិត្តដោយភាគីណាមួយនោះ ។

---

[57] វិធាន ៧១-៧២ នៃវិធានផ្ទៃក្នុង ។

[58] មាត្រា ៧ នៃកិច្ចព្រមព្រៀង ។ មាត្រា ២០(ថ្មី) ២៣(ថ្មី) នៃច្បាប់ អ.វ.ត.ក ។

២៨. ស្រដៀងគ្នានេះដែរ មាត្រា ២៦៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បាន ចែងដាក់កម្រិតអំពីសិទ្ធិប្តឹងឧទ្ធរណ៍ទៅលើសេចក្តីសម្រេចរបស់ចៅក្រមស៊ើបអង្កេត។ មាត្រា នេះ មិនបានគិតទុកអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាណាមួយ ដែលបដិសេធការបកប្រែ ឯកសារទៅជាភាសារបស់ចុងចោទ ឬរបស់មេធាវីចុងចោទឡើយ ។

២៩. សរុបសេចក្តីមក បញ្ហាទាក់ទងនឹងការបកប្រែ មិនមែនជាប្រភេទនៃបញ្ហាដែលអាចប្តឹង ឧទ្ធរណ៍បាននោះទេទោះបីជាស្ថិតនៅក្រោមអំណាចនៃការធ្វើសេចក្តីសម្រេច របស់សហ ចៅក្រមស៊ើបអង្កេតក៏ដោយ ។ ការបកប្រែ គឺជាកិច្ចការរបស់រដ្ឋបាលតុលាការ ស្ថិតនៅក្នុង វិសាលភាពដែលថា អ្នកគ្រប់គ្រងបញ្ជីនៅបណ្តាតុលាការអន្តរជាតិខ្លះត្រូវគ្រប់គ្រងលើកិច្ចការ នេះ[59] ។ ជាលទ្ធផល បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចទាក់ទងនឹងការបកប្រែ គឺវា ហួសពីវិសាលភាពនៃវិធាន ៧៤.៣ ហេតុដូច្នេះ គួរតែត្រូវបានបដិសេធចោល ដោយសារ មិនអាចទទួលយកបាន ។

*ឯកសារទាំងអស់នៅក្នុងសំណុំរឿងមិនបានតម្រូវឱ្យបកប្រែទៅជា ភាសារបស់ចុងចោទនោះទេ*

៣០. ដើមបណ្តឹងឧទ្ធរណ៍លើកឡើងថា ការណ៍ដែលមិនផ្តល់ឱ្យមេធាវីការពារក្តីអន្តរជាតិរបស់គាត់ នូវឯកសារទាំងអស់ជាភាសាបារាំង ដែលមាននៅក្នុងសំណុំរឿង ដែលជាភាសាតែមួយគត់ ដែលគាត់អាចយល់បាន សេចក្តីសម្រេចស្តីពីការបកប្រែនោះ រំលោភលើសិទ្ធិក្នុងការធ្វើ តំណាងប្រកបដោយប្រសិទ្ធិភាពរបស់ដើមបណ្តឹងឧទ្ធរណ៍ ដោយមេធាវីការពារក្តីរបស់គាត់[60] ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ការអះអាងនេះគឺជាការយល់ខុសទាំងទៅលើអង្គហេតុ និង អង្គច្បាប់ ។

---

[59] សេចក្តីសម្រេចលើករណីរបស់ Muhimana, កថាខណ្ឌទី ១០, ១៣ ។

[60] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី ៧ ។

៣១. ទី១ ដូចបានរៀបរាប់ខាងលើ នៅពេលដែលភាគីប្តឹងឧទ្ធរណ៍មានសិទ្ធិក្នុងការទទួលនូវឯកសារមួយចំនួន (មិនទាំងអស់ទេ) ជាភាសាដែលគាត់អាចយល់បាននោះគឺគាត់គ្មានសិទ្ធិក្នុងការទទួលឯកសារឬឯកសារដទៃទៀតដែលជាភាសារបស់មេធាវីការពារក្តីរបស់ខ្លួននោះទៀតទេ ។ ភាគីប្តឹងឧទ្ធរណ៍ អះអាងថា ខ្លួនអាចយល់ និងចេះនិយាយគ្រប់ភាសាផ្លូវការទាំងបីរបស់តុលាការនេះបានដោយស្ទាត់ជំនាញដូចគ្នា ។ ភាសាខ្មែរ គឺជាភាសាកំណើតរបស់គាត់ ។ ភាសាបារាំង គឺជាភាសាដែលគាត់បានសិក្សាក្នុងនាមជានិស្សិតមួយរូប ហើយដែលធ្លាប់បាននិយាយ និងសរសេរក្នុងឋានៈរបស់គាត់ជាមន្ត្រីជាន់ខ្ពស់បំផុតមួយរូប ដែលតំណាងឱ្យ *ខ្មែរក្រហម* ចាប់តាំងពីមុន ក្នុង និងក្រោយពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ទន្ទឹមនឹងនេះ គាត់មានភាពស្ទាត់ជំនាញខាងភាសាអង់គ្លេសដែលបានបង្ហាញតាមរយៈសុន្ទរកថាសាធារណៈផ្សេងៗរបស់គាត់[61] ។

៣២. ទី២ គឺដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម និងដីកាសន្និដ្ឋានស្ពាពរមកទល់ពេលនេះ គឺមានត្រៀមរួចជាស្រេចហើយជាភាសាខ្មែរ និងយ៉ាងហោចណាស់មានភាសាផ្លូវការមួយទៀតរបស់តុលាការនេះ សម្រាប់ភាគីប្តឹងឧទ្ធរណ៍ ។ សហចៅក្រមស៊ើបអង្កេត បានចេញដីកាសម្រេចរួចហើយឱ្យបកប្រែជាភាសាខ្មែរនូវរាល់លេខយោងជើងទំព័រ និងរាល់សញ្ញាបង្ហាញអំពីធាតុផ្សំខាងអង្គហេតុទាំងអស់ ដែលបានភ្ជាប់នៅក្នុងនោះឱ្យទៅជាភាសាខ្មែរ ។ លើសពីនេះ ឯកសារភស្តុតាងភាគច្រើនដែលបានបង្កើតទៅជាផ្នែកនៃសេចក្តីសន្និដ្ឋានទាំងនោះ ដែលរួមមានចម្លើយសាក្សីភាគច្រើនត្រូវបានធ្វើជាកំណត់ហេតុ និងពាក្យបណ្តឹងនានារបស់ជនរងគ្រោះដែលបានទទួលមក ត្រូវបានបកប្រែឱ្យមានស្រាប់ជាភាសាខ្មែរ និង/ឬ ជាភាសាបារាំង ។

---

[61] បទសម្ភាសន៍ជាមួយនឹង ខៀវ សំផន នៅខែកុម្ភៈ ២០០៤, http://www.youtube.com/watcj?v=pTelCN41Oqw&feature=related (time mark 4:00-8:10)

៣៣. ទី៣ គឺបន្ទាប់ពីការចាប់ផ្តើមកិច្ចស៊ើបសួរ ឯកសារភស្តុតាងស្ទើរតែទាំងអស់ ដែលបង្កើតឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលរួមមាន កម្រងឯកសារភស្តុតាង និងភស្តុតាងជាសក្ខីកម្មគឺសុទ្ធតែអាចរកបានជាភាសាខ្មែរ និង/ឬ ភាសាបារាំងស្រាប់ ។ និន្នាការដដែលនេះ ត្រូវបានរំពឹងទុកថា នឹងត្រូវបានបន្តធ្វើតទៅទៀតនៅក្នុងពេលអនាគត ។

៣៤. ទី៤ គឺសេចក្តីណែនាំអនុវត្តតម្រូវឱ្យរាល់សារណាទាំងអស់ដែលដាក់ជូនចំពោះមុខតុលាការនេះយ៉ាងហោចណាស់ក៏ត្រូវធ្វើជាភាសាខ្មែរ និងភាសាជាផ្លូវការណាមួយផ្សេងទៀតដែរ ។ សហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំ ជម្រះបានអនុម័តនូវការចេញសេចក្តីសម្រេចនានារបស់ខ្លួនជាភាសាខ្មែរ និងយ៉ាងហោច ជាភាសាផ្លូវការណាមួយផ្សេងទៀតដែរ ។

៣៥. ទី៥ គឺឯកសារនានាដែលបង្កើតតុលាការនេះ តម្រូវឱ្យក្រុមមេធាវីការពារក្តីតំណាងឱ្យចុងចោទ[62] លើកឡើងឱ្យបានពេញលេញអំពីបញ្ហាផ្សេងៗខាងភាសាសាស្ត្រ និងខាងអង្គច្បាប់ ។ ស្របគ្នានេះដែរ ដើមបណ្តឹងឧទ្ធរណ៍ត្រូវបានផ្តល់ជូននូវមេធាវីអន្តរជាតិមួយរូបដែលបានធ្វើការងារដោយ"រួមសហការគ្នា" ជាមួយក្រុមមេធាវីខ្មែររបស់គាត់ ។ មេធាវីការពារក្តីខ្មែរពីមុន និងបច្ចុប្បន្នរបស់ចុងចោទ គឺលោក សាយ បូរី និងលោក ស ស៊ីវាន អាចយល់ និងអាចធ្វើការងារភាសាខ្មែរ និងជាភាសាបារាំងបានដោយងាយស្រួលដូចគ្នា ដោយសារតែបទពិសោធន៍ផ្សេងៗដ៏ទូលំទូលាយ ហើយនិងការធ្លាប់ចូលរួមចំណែករបស់គាត់នៅក្នុងស្ថាប័នផ្នែកច្បាប់នានារបស់កម្ពុជា ។ មេធាវីការពារក្តីអន្តរជាតិរបស់ភាគីប្តឹងឧទ្ធរណ៍ចេះនិយាយ ភាសាបារាំង និងអង់គ្លេស ហើយក៏ធ្លាប់មានបទពិសោធន៍យ៉ាងទូលំទូលាយអំពីប្រទេសកម្ពុជាដោយធ្លាប់បានមកធ្វើទស្សនកិច្ចជាច្រើនលើកច្រើនសារ[63] ។ ក្រុមមេធាវីការពារក្តីរបស់ភាគីប្តឹងឧទ្ធរណ៍មានអ្នកច្បាប់ខ្មែរមួយរូបបន្ថែមទៀត គឺលោកស្រី សេង សុជាតា ដែលធ្លាប់បានទៅសិក្សានៅប្រទេសបារាំង ហើយដែលអាចនិយាយ និងយល់ភាសាខ្មែរ បារាំង និងភាសា

---

[62] សេចក្តីសម្រេចទាក់ទងនឹងការបកប្រែ, ទំព័រទី ៣ ។

[63] http://www.avocatparis.org/Eannuaire/Resultat2.aspx?cnbf=14610(Record maintained by the Bar of Paris)

អង់គ្លេសបានដោយងាយស្រួល ។ បន្ថែមលើនេះ ក្រុមមេធាវីការពារក្ដីរបស់ភាគីប្ដឹងឧទ្ធរណ៍ រួមមាន មេធាវីជនជាតិបារាំងម្នាក់ ដែលមានបទពិសោធន៍ គឺលោកស្រី Charlotte MOREAU ក្នុងឋានៈជាទីប្រឹក្សាច្បាប់អន្តរជាតិ និងលោកស្រី Julie BARDECHE ក្នុងឋានៈជាកម្មសិក្សាការីផ្នែកច្បាប់រយៈពេលយូរមួយរូប ។ លោកស្រី MOREAU និងលោកស្រី BARDECHE ទាំងពីរនាក់គឺសុទ្ធតែចេះនិយាយភាសាបារាំង និងអង់គ្លេសបានយ៉ាងស្ទាត់ជំនាញ ។ ក្នុងចំណោមពួកមេធាវីការពារក្ដីជាតិ និង អន្តរជាតិទាំងនេះសុទ្ធតែអាចសហការគ្នាដើម្បី "ធ្វើឱ្យសមត្ថភាពខាងភាសាសាស្ត្រនៃការិយាល័យរបស់ពួកគេមានលក្ខណៈល្អប្រសើរបំផុត" ដើម្បីអាចដោះស្រាយចំពោះកង្វល់ផ្សេងៗ របស់ភាគីប្ដឹងឧទ្ធរណ៍ ដែលនៅក្នុងសំណុំរឿងមិនមានឯកសារជាភាសាខ្មែរ ដែលគាត់អាចបើកមើលបាន[64] ។

៣៦. ទី៦ គឺឯកសារនានាដែលមានស្រាប់ជាភាសាខ្មែរ និងឯកសារទាំងឡាយដែលបានបង្គាប់ឱ្យផ្ដល់ជាភាសាខ្មែរនៅក្នុងសេចក្ដីសម្រេចស្ដីពីការបកប្រែ បានរំលេចឱ្យឃើញពីរបបមួយដែលមានលក្ខណៈសេរីបំផុតក្នុងការដាក់បង្ហាញឯកសារដែលតុលាការ ICTY និង ICTR បានប្រកាន់យក ។ ឯកសារជាមូលដ្ឋានរបស់តុលាការ ICC-ត្រូវបានគេធ្វើព្រាងនៅក្នុងពេលក្រោយមកទៀត និងដែលបានសំដែងឱ្យឃើញពីនិមិត្តរូបនៃច្បាប់អន្តរជាតិដ៏ជាក់លាក់អំពីបញ្ហាទាំងនោះ ទោះបីជាមានភាពច្បាស់ជាងក៏ដោយក៏នៅមានការរឹតត្បឹតជាងដែរ ។ ក្រៅពីឯកសារចំបងមួយចំនួននេះ តុលាការបានអនុម័តនូវគោលការណ៍ស្ដីពីការបង្កើនបន្ថែមសមត្ថភាពខាងភាសាសាស្ត្ររបស់ក្រុមមេធាវីការពារក្ដីនានាដើម្បីនឹងធានាឱ្យបានថា ចុងចោទអាចនឹងចូលរួមបានដោយប្រសិទ្ធិភាពនៅក្នុងការការពារក្ដីរបស់ខ្លួនផ្ទាល់ ។ សហចៅក្រមស៊ើបអង្កេត បានអនុម័តនូវវិធីសាស្ត្រកូនកាត់នៃវិធីសាស្ត្រទាំងពីរនេះដែលមិនធ្វើឱ្យខូចទៅដល់សិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយត្រឹមត្រូវណាមួយរបស់ចុងចោទនោះទេ ។

៣៧. ទី៧ នៅពេលដែលសហចៅក្រមស៊ើបអង្កេតបានសម្រេចបង្គាប់ឱ្យផ្ដល់នូវឯកសារសំខាន់ៗមួយចំនួនជាភាសាដែលជនត្រូវចោទអាចយល់បាននោះ គឺសហចៅក្រមស៊ើបអង្កេតមិន

---

[64] សេចក្ដីសម្រេចទាក់ទងនឹងការបកប្រែ, កថាខណ្ឌ A4 ។

បានរារាំងមិនឱ្យក្រុមមេធាវីការពារក្តីធ្វើសំណើសុំទៅផ្នែកគ្រប់គ្រងតុលាការ សុំឱ្យបកប្រែឯកសារដោយផ្អែកទៅលើមូលដ្ឋាននៃបញ្ជីរួម និងដែលកំណត់អំពីអាទិភាពនៃឯកសារបន្ទាន់ជាងគេបំផុតដែលបានតម្រូវដោយអ្នកទទួលដែលមានចំនួនច្រើនជាអតិបរិមានោះទេ ។ តាមពិត ក្រុមការងារបកប្រែរួមមានតំណាងពីអង្គភាពគាំពារការការពារក្តីចំនួនមួយរូបផងដែលតែងតែជួបប្រជុំគ្នានិងដំណើរការការងារនៅក្នុងបរិវេណនៃទីតាំងនេះ ។

៣៨. ដើមបណ្តឹងឧទ្ធរណ៍ បានចោទសួរអំពីការប្រើយុត្តិសាស្ត្ររបស់តុលាការ ICTY ICTR និង ICC នៅក្នុងដំណើរការនីតិវិធីនៅចំពោះមុខតុលាការនេះ ដោយផ្អែកលើហេតុផលថា ប្រព័ន្ធច្បាប់ ទាំងពីរនេះគឺខុសគ្នា[65] ។ គាត់បានទាមទារថា នៅចំពោះមុខតុលាការនេះមានចុងចោទមួយរូបចូលរួមនៅក្នុងដំណើរការនីតិវិធី តាំងពីយូរមុនពេលគាត់ចូលរួមនៅក្នុងតុលាការទាំងនោះទៅទៀត ហេតុដូច្នេះហើយ សិទ្ធិក្នុងការប្រើប្រាស់សេវាបកប្រែ ត្រូវតែបានផ្តល់ឱ្យនៅក្នុងដំណាក់កាលតាំងពីយូរមុននេះមកម្ល៉េះ ដោយរួមទាំងសិទ្ធិក្នុងការពិនិត្យមើលភស្តុតាងដោះបន្ទុកផង ដើម្បីធ្វើឱ្យគាត់អាចមានលទ្ធភាពចូលរួមនៅក្នុងការស៊ើបសួរបានដោយប្រសិទ្ធិភាព ។ សហព្រះរាជអាជ្ញា ធ្វើការកត់សំគាល់ថា នៅពេលដែលអាចនឹងមានការខុសគ្នាជាលក្ខណៈប្រព័ន្ធនោះ ដំណោះស្រាយតាមផ្លូវច្បាប់ដែលត្រូវបានកំណត់ដោយវិធាននានា និងដែលត្រូវបានបញ្ជាក់នៅក្នុងដីកាសម្រេចស្តីពីការបកប្រែ បានធ្វើឱ្យកើតមាននូវការខុសគ្នាទាំងនោះ បើសិនជាមានការខុសគ្នាណាមួយដែលមិនមានផលវិបាក ។ នៅពេលដែលមានការពិតថា ក្នុងពេលភ្លាមៗបន្ទាប់ពីចូលរួមនៅក្នុងកិច្ចស៊ើបសួរ នៅក្នុងពេលសវនាការដេញដោល ចុងចោទត្រូវបានអញ្ជើញឱ្យដាក់សារណាអំពីភស្តុតាងសំខាន់ៗនោះ សិទ្ធិពិនិត្យមើលឯកសាររបស់គាត់អាចនឹងត្រូវបានបង្កលក្ខណៈងាយស្រួល ដោយសារកិច្ចសហការក្នុងរង្វង់ក្រុមមេធាវីរបស់គាត់ និងដោយសារការជួយឧបត្ថម្ភពីផ្នែកគាំពារការការពារក្តី ។ បន្ថែមលើនេះ មិនមានការយល់ព្រមទូលំទូលាយទៅលើសិទ្ធិក្នុងការផ្តល់ឯកសារដោះបន្ទុកជាភាសារបស់ចុងចោទនោះទេ ។ នៅពេលដែលតុលាការ *ពិសេស* បានផ្តល់ឱ្យនូវឯកសារនេះ តុលាការ ICC មិនបានផ្តល់ឱ្យទេ ។

---

[65] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី ៣២ និង កថាខណ្ឌបន្តបន្ទាប់ទៀត ។

៣៩. ការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌ ដែលតម្រូវឱ្យផ្តល់ឯកសារជាភាសាដែលចុងចោទអាចយល់បាននោះគឺត្រូវបានបំពេញឱ្យបានគ្រប់គ្រាន់ដោយដំណោះស្រាយ ចំពោះសមត្ថភាពពេញលេញខាងភាសាសាស្ត្ររបស់ក្រុមមេធាវីការពារក្តី ចំពោះធនធានរបស់ផ្នែកគាំពារការការពារក្តី ចំពោះអ្នកបកប្រែសរសេរធ្វើការពេញម៉ោង ដែលត្រូវបានចាត់តាំងដូចនៅក្នុងសេចក្តីសម្រេចទាក់ទងនឹងការបកប្រែភាសា និងចំពោះការខិតខំប្រឹងប្រែងរបស់ផ្នែកគ្រប់គ្រងតុលាការ ដើម្បីផ្តល់នូវសេវាបកប្រែឯកសារឱ្យបានទាន់ពេលវេលា ។ ទោះជាយ៉ាងណាក្តី សេចក្តីសម្រេចទាក់ទងនឹងការបកប្រែ មិនបានចែងកំណត់អំពីសិទ្ធិទទួលបាន ការបកប្រែ និងអំពីកាតព្វកិច្ចរបស់ភាគីនានា នៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការ នីតិវិធីនោះ ។ ក្នុងដីកាសម្រេចនោះគ្រាន់តែនិយាយថា អង្គជំនុំជម្រះសាលាដំបូង និងអង្គបុរេជំនុំជម្រះដែលសេចក្តីសម្រេចនោះមិនអាចភ្ជាប់កាតព្វកិច្ច អាចធ្វើសេចក្តីសម្រេចបែបដូច្នេះ បានតាមការដែលពួកគេយល់ឃើញថាជាការសមស្រប ។

*សេចក្តីសម្រេចទាក់ទងនឹងការបកប្រែ បានការពារសិទ្ធិក្នុងការធ្វើតំណាង ដ៏មានប្រសិទ្ធិភាពរបស់ចុងចោទ*

៤០. ដើមបណ្តឹងឧទ្ធរណ៍បានទាមទារថា សិទ្ធិរបស់ខ្លួនដែលត្រូវតំណាងដោយមេធាវីការពារក្តីអន្តរជាតិមួយរូបដ៏មានប្រសិទ្ធិភាព ត្រូវបានរំលោភបំពាន ដោយសារតែការខកខាននៃសេចក្តីសម្រេចស្តីពីការបកប្រែ មិនបានបង្គាប់ឱ្យធ្វើការបកប្រែគ្រប់ឯកសារទាំងអស់នៅក្នុងសំណុំរឿងឱ្យទៅជាភាសាបារាំង ដែលជាភាសារបស់មេធាវីការពារក្តីអន្តរជាតិរបស់គាត់[66] ។ ជាក់ស្តែង គឺមិនមានលិខិតុបករណ៍អន្តរជាតិណាមួយ ដែលធានាថាគ្រប់ឯកសារទាំងអស់នៅក្នុងសំណុំរឿងរបស់ចុងចោទត្រូវបានបកប្រែ ទៅជាភាសារបស់មេធាវីការពារក្តីរបស់ចុងចោទនោះ ជាពិសេស គឺនៅពេលដែលរឿងនេះមិនត្រូវបានទាមទារឱ្យធ្វើទៅជាភាសារបស់ចុងចោទ ។ នៅពេលណាក៏ដោយ មិនសូវមានករណីដែលតុលាការអន្តរជាតិផ្តល់ការ

---

[66] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី ៥៦ និង កថាខណ្ឌបន្តបន្ទាប់ទៀត ។

អនុញ្ញាតលើសំណើបែបនេះទេ តុលាការអន្តរជាតិទាំងនោះបានលើកទឹកចិត្តដល់ក្រុមមេធាវីការពារក្តីនានាឲ្យប្រើប្រាស់នូវសមត្ថភាពផ្នែកភាសាសាស្ត្រ ដែលមានស្រាប់នៅនឹងកន្លែង ដើម្បីដោះស្រាយឲ្យបានចំពោះការខ្វះខាតសមត្ថភាពខាងភាសាសាស្ត្ររបស់មេធាវីណាមួយនៅក្នុងភាសារបស់ចុងចោទ ។ ហេតុដូច្នេះហើយ សហព្រះរាជអាជ្ញា ធ្វើសេចក្តីសន្និដ្ឋានថា ដើមបណ្តឹងឧទ្ធរណ៍មិនមានសិទ្ធិបែបនេះជាប់មកជាមួយស្រាប់នោះទេ ។ អាស្រ័យហេតុនេះ គាត់មិនអាចលើកយកសិទ្ធិនេះមកប្រើដើម្បីតវ៉ាទាមទារអំពីការមានមេធាវីតំណាង ដោយមិនមានប្រសិទ្ធិភាពបានឡើយ ។

៤១. បណ្តឹងឧទ្ធរណ៍ខកខានមិនបានទទួលស្គាល់លក្ខណៈពិសេសរបស់តុលាការនេះ ដែលនៅគ្រប់ជាន់ថ្នាក់ទាំងអស់ - រួមទាំងនៅក្នុងក្រុមមេធាវីការពារក្តីផង - ដែលមានបុគ្គលិកបរទេសធ្វើការងារយ៉ាងជិតស្និទ្ធជាមួយបុគ្គលិកខ្មែរជាដៃគូររបស់ខ្លួន ដើម្បីជួយគាំទ្រដល់សមត្ថភាពខាងផ្នែកភាសាសាស្ត្រ និងផ្នែកច្បាប់ជាសមូហភាព ។ មេធាវីការពារក្តីអន្តរជាតិមិនធ្វើការទោលតែម្នាក់ឯងដាច់ដោយឡែកពីគេនោះទេ ។ មេធាវីអន្តរជាតិត្រូវបានគេរំពឹងទុកថា គាត់ត្រូវធ្វើការងារដោយសហការគ្នាជាមួយនឹងមេធាវីខ្មែរ ហើយត្រូវប្រើប្រាស់នូវសមត្ថភាពខាងផ្នែកភាសាសាស្ត្រតាមដូចដែលបានផ្តល់ជូន និងដែលមានស្រាប់នៅក្នុងក្រុមមេធាវីការពារក្តី ។ តាមពិត សេចក្តីសម្រេចស្តីពីការបកប្រែនេះ បានជួយបង្កើនសមត្ថភាពផ្នែកភាសាសាស្ត្រ តាមរយៈការផ្តល់ជូនបន្ថែមដល់ក្រុមមេធាវីការពារក្តីនីមួយៗ នូវអ្នកបកប្រែសរសេរម្នាក់ទៀត ។

៤២. ថ្វីត្បិតតែមិនមានការទទួលស្គាល់អំពីសិទ្ធិដែលត្រូវមានឯកសារនានាជាភាសារបស់មេធាវីការពារក្តីអន្តរជាតិក៏ដោយ ក៏នៅពេលដែលគាត់មិនចេះនិយាយភាសារបស់ចុងចោទនោះ សេចក្តីសម្រេចទាក់ទងនឹងការបកប្រែនេះ បានព្យាយាមឲ្យបង្កើតជាយន្តការមួយ សម្រាប់ក្រុមមេធាវីការពារក្តីនានាដើម្បីទទួលបានសេវាបកប្រែភ្លាមៗនូវឯកសារនានាឲ្យទៅជាភាសាផ្សេងៗក្រៅពីភាសាខ្មែរ ។ សេចក្តីសម្រេចនេះ បានចែងអំពីតម្រូវការបុគ្គលិកបន្ថែមដែលត្រៀមសម្រាប់តែបកប្រែដើម្បីធានាឲ្យប្រាកដថា ឯកសារអ្វីក៏ដោយដែលត្រូវឲ្យធ្វើការបក

ប្រែជាប្រញាប់ ឬដោយឥតបានព្រាងទុក អាចមាននៅនឹងកន្លែងស្រាប់ ដោយសារមានជំនួយពីពួកអ្នកបកប្រែសរសេរដោយមិនគិតកម្រៃដែលមានស្រាប់នៅនឹងកន្លែង ។

*ដីកាសម្រេចស្តីពីការបកប្រែធានាឲ្យប្រាកដនូវគោលការណ៍ស្តីពីសមភាពនៃអំណាច*

៤៣. ដើមបណ្តឹងឧទ្ធរណ៍បានតវ៉ាជំទាស់ថា ដីកាសម្រេចស្តីពីការបកប្រែព្យាយាមធ្វើការផ្លាស់ប្តូរគោលការណ៍ស្តីពីសមភាពនៃអំណាច ដោយដាក់បន្ទុកការបកប្រែទៅលើមេធាវីការពារក្តីទៅវិញ ហេតុដូចនេះ គឺវាផុតពី "សមត្ថកិច្ចរបស់រដ្ឋ" ដែលជាធម្មតា គឺរដ្ឋជាអ្នកដែលត្រូវផ្តល់នូវសេវាបកប្រែនេះ[67] ។

៤៤. ដោយក្នុងការផ្តល់អ្នកបកប្រែសរសេរមួយរូបជាក់លាក់ សម្រាប់ក្រុមមេធាវីការពារក្តីនីមួយៗនោះ ដីកាសម្រេចស្តីពីការបកប្រែ មិនបានព្យាយាមដើម្បីផ្ទេរបន្ទុកក្នុងការបកប្រែទៅឲ្យក្រុមមេធាវីការពារក្តីនោះទេ ។ តាមពិត ការផ្តល់បន្ថែមនូវធាតុបករណ៍ជំនួយបន្ថែមនេះមិនបានបង្កើតនូវកាតព្វកិច្ចថ្មីណាមួយទៅឲ្យមេធាវីការពារក្តីនោះទេ ក៏ប៉ុន្តែខំស្វែងរកការបំពេញបន្ថែមទៅលើសមត្ថភាពខាងភាសាសាស្ត្រដែលមានស្រាប់តែប៉ុណ្ណោះ ដើម្បីនឹងជួយលើកស្ទួយថែមទៀតដល់សិទ្ធិរបស់ចុងចោទក្នុងការមានមេធាវីតំណាងដោយប្រសិទ្ធិភាព ។ ដីកាសម្រេចស្តីពីការបកប្រែ បានបញ្ជាក់យ៉ាងច្បាស់ថា គោលបំណងនៃវិធានការនេះ គឺ "ដើម្បីធ្វើឲ្យប្រាកដថា ជនត្រូវចោទ និងក្រុមមេធាវីការពារក្តីរបស់គេអាចមានឯកសារដែលបានបកប្រែរួចជាស្រេចមួយចំនួនតាមតម្រូវការ ដើម្បីវាយតម្លៃអំពីតម្រូវការក្នុងការបកប្រែរបស់ក្រុមមេធាវីការពារក្តីដែលត្រូវបញ្ជូនទៅឲ្យផ្នែកគ្រប់គ្រងតុលាការ និងដើម្បីជួយដល់កិច្ចសហការរបស់ក្រុមមេធាវីទាំងនោះជាមួយផ្នែកគ្រប់គ្រងតុលាការ"[68] ។ អាស្រ័យហេតុនេះ បន្ទុករបស់ផ្នែកគ្រប់គ្រងតុលាការក្នុងកំរិតដែលត្រូវបានកំណត់ឲ្យទាំងប៉ុន្មាននោះ គឺមិនត្រូវបានធ្វើការផ្ទេរនោះទេ ។ ផ្ទុយទៅវិញ គឺក្រុមមេធាវីការពារក្តីនឹងកាន់តែត្រូវបានពង្រឹងថែមទៀតដើម្បីឲ្យបានស្ថិតនៅក្នុងស្ថានភាពមួយដ៏ល្អប្រសើរ ក្នុងការប្រើប្រាស់សេវាបកប្រែរបស់

---

[67] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី ៤៧ ។

[68] សេចក្តីសម្រេចទាក់ទងនឹងការបកប្រែ, កថាខណ្ឌ E.4 ។

ផ្នែកគ្រប់គ្រងតុលាការនោះ ។ អ្នកបកប្រែថ្មីៗទាំងនោះ ទំនងជានឹងជួយដល់ក្រុមមេធាវីការពារក្តីនានាផងដែរក្នុងការធានាឲ្យប្រាកដថា ធនធាននានារបស់ផ្នែកគ្រប់គ្រងតុលាការនឹងត្រូវបានគេយកទៅប្រើប្រាស់ដោយមានប្រសិទ្ធិភាព និងបានយ៉ាងល្អប្រសើរបំផុត ។

៤៥. សហព្រះរាជអាជ្ញា រំពឹងទុកជាមុនថា ការផ្តល់អ្នកបកប្រែឯកសារ នឹងជួយដល់ក្រុមមេធាវីការពារក្តីនានានៅក្នុងករណីដែលតម្រូវការក្នុងការបកប្រែ ត្រូវបានកំណត់យកក្នុងរយៈពេលដ៏ខ្លី ដោយឥតព្រាងទុកជាមុន ឬបន្ទាន់ភ្លាមៗ ។ ស្របតាមយុត្តិសាស្ត្រអន្តរជាតិ ការណ៍នេះត្រូវបានភ្ជាប់កាតព្វកិច្ចឡើងវិញជាថ្មីទៅនឹងសិទ្ធិរបស់ចុងចោទ និងមិនត្រូវបង្កើតនូវកាតព្វកិច្ចបន្ថែមទៀតដល់ក្រុមមេធាវីការពារក្តីទេ ។

៤៦. សេចក្តីសំអាងទាក់ទិនទៅនឹងគោលការណ៍ស្តីពីសមភាពនៃអំណាច គួរតែត្រូវបានច្រានចោលផងដែរ ដោយផ្អែកលើទឡ្ហីករណ៍បន្ថែមដែលថា ភាគីប្តឹងឧទ្ធរណ៍បានជ្រើសរើសមិនប្រើប្រាស់នូវធាតុបករណ៍ណាមួយ ដែលផ្នែកគ្រប់គ្រងតុលាការបានផ្តល់ជូនសម្រាប់ការបកប្រែឯកសារ ។ ជាពិសេស ភាគីប្តឹងឧទ្ធរណ៍ មិនបានឆ្លើយតបទៅនឹងសេចក្តីណែនាំនៅក្នុងសេចក្តីសម្រេចទាក់ទងនឹងការបកប្រែ ដែលបានស្វែងរកនូវការដាក់សារណាផ្សេងៗពីសំណាក់ក្រុមមេធាវីការពារក្តី ពាក់ព័ន្ធនឹងការដាក់អាទិភាពលើសំណើសុំការបកប្រែ[69] ។

## ៦. សេចក្តីសន្និដ្ឋាន

៤៧. សហព្រះរាជអាជ្ញា ស្នើឲ្យ អង្គបុរេជំនុំជម្រះ បដិសេធបណ្តឹងឧទ្ធរណ៍នេះចោល ដោយហេតុថា មានកំហុសនីតិវិធីដែលមិនអាចទទួលយកបាន និងជាសំខាន់ គឺគ្មានអង្គសេចក្តី ។ សហព្រះរាជអាជ្ញា ស្នើឲ្យអង្គបុរេជំនុំជម្រះ សម្រេចយ៉ាងដូច្នេះ ពីព្រោះថាសេចក្តីសម្រេចទាក់ទង

---

[69] *ករណីរបស់ ខៀវ សំផន*, សំណើសុំបញ្ចូលអនុសារណៈរបស់ប្រធានផ្នែកតុលាការទាក់ទងទៅនឹងដីកាសម្រេចស្តីពីភារកិច្ច និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែរបស់សហចៅក្រមស៊ើបអង្កេត ក្នុងសំណុំរឿងលេខ ០០២, សំណុំរឿងព្រហ្មទណ្ឌលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស, ចុះថ្ងៃទី២១ សីហា ២០០៨, លេខERN 00219017-00219019, A130/9.. ។

នឹងការបកប្រែនេះ មិនបំពានលើសិទ្ធិក្នុងការទទួលបាននូវការកាត់ក្តីដ៏ត្រឹមត្រូវណាមួយរបស់ភាគីប្តឹងឧទ្ធរណ៍នោះទេ ហើយក៏មិនមានការបំពានលើនីតិវិធីនោះដែរ ។ អាស្រ័យហេតុដូច្នេះ ភាគីប្តឹងឧទ្ធរណ៍ មិនមានសិទ្ធិទទួលបាននូវដំណោះស្រាយណាមួយដែលជាផលវិបាក ក៏ដូចជាសិទ្ធិក្នុងការដោះលែងផងដែរ ។

៤៨. ហេតុដូចនេះ ពាក្យសុំរបស់ភាគីប្តឹងឧទ្ធរណ៍សំរាប់សវនាការសាធារណៈនៃបណ្តឹងឧទ្ធរណ៍នេះ ក៏គួរតែត្រូវបដិសេធចោលផងដែរ[70] ។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨
**សហព្រះរាជអាជ្ញា**

**លោក យ៉េត ចរិយា**
**សហព្រះរាជអាជ្ញារង**

**លោក** William SMITH
**សហព្រះរាជអាជ្ញារង**

70 *ករណីរបស់ ខៀវ សំផន,* ពាក្យសុំឱ្យមានសវនាការជាសាធារណៈស្តីពីបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងការបដិសេធការបកប្រែសំណុំរឿងព្រហ្មទណ្ឌរបស់លោក ខៀវ សំផន, សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ-១១) ចុះថ្ងៃទី១១ សីហា ២០០៨, លេខERN 00218008-00218012, A190/I/2 ។